

# ការស្នេហាជាតិ, ការជឿ, ការសង្ឃឹម

សេរីការ

ជាតិ និង មាតា មាន ខ្លឹមសារ តែមួយ សំរាប់ កូនខ្មែរ កើតជាខ្មែរ រស់ជាខ្មែរ ដើម្បី ជាតិខេមរា ។ តើ គំនិតនេះ ជា គំនិត ប្រាកដ ដែរឬទេ ?

នៅក្នុង គំនិត ស្នេហាជាតិ ដែល ជា មនោសញ្ចេតនា ខ្ពស់ដល់កំរិត នៃ ជនជាតិ នីមួយៗ ចំពោះ ប្រជាជាតិ របស់ខ្លួន, គេ តែង ប្រៀបធៀប មាតា ទៅនឹង ជាតិ ដើម្បី សម្តែង អោយឃើញ នូវ ទឹកចិត្តស្នេហាជាតិ ។ សួរជាសំណួរថា តើ សេចក្តីស្នេហាជាតិ មានរូបភាពបែបណា ? ជា ពលិកម្ម ក្នុងចិត្តឆន្ទ:នៃបុគ្គលហ៊ានស្លាប់ ដើម្បី ជាតិ ដែល គេ ទុកជា វិរបុរស, ជា អ្នកការពារជាតិ តាម លទ្ធភាព ដែលខ្លួនមាន, ជា ពលរដ្ឋ ចេះដឹង និង អនុវត្ត ទៀងប្រយ័ត្នប្រយែង នូវ សិទ្ធិ និង ករណីយកិច្ច ជា ពលរដ្ឋ តាមច្បាប់ជា ធរមាន ។ បើយើងយក កត្តា ទាំងបីនេះ មក ពិចារណា យើងឃើញ ថា សេចក្តីស្នេហាជាតិ មាន សញ្ញាណ បីយ៉ាង៖ ១. អ្វីដែលកើតពីចិត្ត, ២. អ្វីដែលត្រូវធ្វើ, ៣.អ្វីដែលត្រូវគោរព ។ នៅក្នុង សញ្ញាណ ទាំងបីយ៉ាងនេះ វាមានគោលគំនិតធំពីរយ៉ាង៖ ១. ការជឿ (la foi), ២. ការសង្ឃឹម (l’espérance) ។ ការជឿ គឺ ជឿ លើ អ្វីមួយ ដែល នៅក្រៅចិត្ត គឺថា វត្ថុនៅក្រៅនោះ ជរនចិត្តទៅរកជំនឿ លើខ្លួន ; រីឯ ការសង្ឃឹម វិញ គឺ មាននៅក្នុងចិត្ត ហើយ ចេញពីចិត្ត ជឿ ទៅលើ អ្វីមួយ ដែល នៅពី ក្រៅចិត្ត ។ រួមសេចក្តីមក យើងអាច និយាយជាសង្ខេបបានថា ការជឿ គឺមាន កម្លាំងក្រៅ ឆក់ទាញចិត្ត, ចំណែក ការសង្ឃឹម គឺ កម្លាំងក្នុងចិត្ត ឆក់យក អ្វីមួយ ដែល ចិត្ត មាន សង្ឃឹម ចំពោះ

វាៗ បើយើង យក សញ្ញាណ ទាំងនោះ មក ដាក់នៅក្នុង សេចក្តីស្នេហាជាតិ វិញ តើ វា នឹងមាន សារជាតិ បែបណា?

ជាតិ ជា សញ្ញាណ អរូបិយ ទោះបី ខ្លួន មាន លក្ខណ: អតិសេដ្ឋ សំរាប់ ប្រជាពលរដ្ឋ, អាស្រ័យហេតុនេះ គេ ត្រូវ អោយ រូបតាពមួយ សំរាប់ សំគាល់ជាតិ ; រូបតាពនោះ គឺ ប្រជាជាតិ ដែលមាន ទឹកដី, ប្រជាពលរដ្ឋ, អ្នកដឹកនាំ, ភាសា, ប្រពៃណីយ និង ប្រវត្តិសាស្ត្រៗ ការបង្ហាញ រូបតាព បែបនេះ គឺ គេ ប្តូរ លក្ខណ: អរូបិយ អោយក្លាយ ជា លក្ខណ:សាមញ្ញ ស្រួល មើលឃើញ រូបតាព នៃ ជាតិៗ តែ រូបតាព បែបនេះ ក៏ អាចចោទជា សំនួរថា តើ សេចក្តីស្នេហាជាតិ គឺ ជា សេចក្តីស្នេហា វត្ថុធាតុ ទាំងអស់ ផ្តុំ ជា ប្រជាជាតិ ឬ អាច មាន សេចក្តីស្នេហាជាតិ លើ ភាគខ្លះៗ បាន ?

បើយក សារព័ន ជា លក្ខន្តិក: ខានមិនបាន គឺ វា ជា ទស្សន: តឹងតែងន័យ ព្រោះគេ ទុក ជាតិ ជា សាកលសរីរ: មិនអាច បែងចែក ជា ភាគបាន, ដូច្នេះ បើ ខ្វះ វត្ថុធាតុ ណាមួយ គឺ ជាតិ គ្មាន ខ្លឹមសារជាតិ នោះឡើយ, ដោយហេតុនេះ សេចក្តីស្នេហាជាតិ គឺជា សេចក្តីស្នេហា ខ្លឹមសារជាតិ នោះឯងៗ គេ អាច ទុក ទស្សន: នេះ ជា ទស្សន: បូរណនិយម (intégrisme) ដែល ពួកអ្នកដឹកនាំ របប សិទ្ធិអំណាច ឬ សមស្តនិយម យកវាមកប្រើ ជា គោលការណ៍ របស់ខ្លួន គឺថា ស្រឡាញ់ជាតិ មិនមែន គ្រាន់តែស្មោះ នឹងខ្លួននោះឡើយ គឺ ត្រូវស្រឡាញ់ ដល់ ខ្លួន ជា ដាច់ខាត ដូចយ៉ាង បង្កើត ពាក្យ បិតាជាតិជា អាទិៗ តែ មាន ទស្សន: រីកសាយន័យ មួយដែរ គឺ ជាតិ ជា ប្រជាពលរដ្ឋ ធិបតេយ្យ ដែល ទុកជាវត្ថុធាតុ សមុដ្ឋាន (primordial) ព្រោះ ជា ម្ចាស់ នៃ ច្បាប់

ទាំងឡាយ នៃ ជាតិ ដែលមាន នីតិរដ្ឋៗ ទស្សនៈ នេះ ជា ទស្សនៈទំនើប ចេញអំពី ដំណើរ នៃ ការលូតលាស់ នៃ បញ្ញា នៃ មនុស្សជាតិ ដែលជា ឧទ័យ (émergence) នូវ អំណាចច្បាប់ លើ អំណាចផ្តាច់ការៗ នៅក្នុងអត្ថរស នៃ ទស្សនៈ នេះ ដែលនាំ បង្កើតបាន នូវ លទ្ធិប្រជាធិបតេយ្យ ដែលជា របបដឹកនាំជាតិ មាន ជោគជ័យ លើ របប ដឹកនាំ ទាំងអស់ មាននៅក្នុងលោក មកដល់ សព្វថ្ងៃ នេះៗ ដោយហេតុនេះ អត្ថន័យ នៃ សេចក្តីស្នេហាជាតិ គឺជា សេចក្តីស្រឡាញ់ នៃ ប្រជាពលរដ្ឋ លើខ្លួនឯង ដែលមានច្បាប់ ជា អ្នកគ្រប់គ្រងៗ សេចក្តីស្នេហា បែបនេះ មិនទុកជា អត្តស្នេហានិយម (narcissisme) នោះឡើយ ព្រោះ ជា សេចក្តីស្រឡាញ់ រួមគ្នា នៅក្នុង ប្រយោជន៍រួម ដើម្បី កសាង នូវ អនាគត សាធារណ៍ (avenir commun) ដែលមាន ប្រជាជាតិ ជាមូលដ្ឋាន នៃ សុខតមកម្ម (harmonisation) របស់ ប្រជាពលរដ្ឋៗ យើង អាច សន្និដ្ឋានបានថា សេចក្តីស្នេហា តាម ទស្សនៈ តឹងតែងន័យ គឺ ជា សេចក្តីស្នេហាជាតិ ជា វត្ថុវិស័យ (objectif) ឬ ការបង្ខំ ដើម្បី បំរើ ប្រយោជន៍ ដែល មាន នរណាម្នាក់ ឬ ក្រុមណាមួយ គេ សម្លឹង ឃើញ នូវ គោលដៅ សំរាប់ ការពារ ឬ ទាញយកបានប្រយោជន៍ ពី សេចក្តីស្នេហានេះ, បើតាម ទស្សនៈ រីកសាយន័យ ឬ ទំនើប វិញ ជា សេក្តីស្នេហាជាតិ បរិសុទ្ធ មិនប្រាថ្នា ប្រយោជន៍ ក្នុង វត្ថុវិស័យ រកចំណេញ ពី សេក្តីស្នេហាជាតិ ព្រោះ ជា សេចក្តីស្នេហាជាតិ នៃ ប្រជាពលរដ្ឋ ដោយប្រជាពលរដ្ឋ និង ដើម្បី ប្រជាពលរដ្ឋ នៅក្នុង ការជឿ ដល់ ភាពឧត្តម នៃ មាតុភូមិ និង ការសង្ឃឹម ដល់ ជាតិ ជា ជម្រក នៃ សន្តិភាព សំរាប់ ការរស់នៅ នៃ ជីវភាពរាល់ថ្ងៃៗ

**១. ការជឿ ដល់ ភាពឧត្តម នៃ មាតុភូមិ** : ជាទូទៅ រូបភាព នេះ គឺជា គុណសម្បត្តិ នៃ ប្រជាពលរដ្ឋ ដែល មាន នៅក្នុង កំណាប់ នៃ បញ្ញាជាតិ និង ការរីកចំរើន នៃ មនុស្សជាតិៗ ដូច្នេះ ការជឿនេះ ជា បឋម គឺ ការជឿ លើ សមត្ថភាពខ្លួនឯង ជា ប្រជាពលរដ្ឋ មាន សហបញ្ញា មាំទាំ ដែលអាច បញ្ចេញអោយឃើញ នូវ សមត្ថភាព និង សមត្ថកិច្ច របស់ បុគ្គល ម្នាក់ៗ ដើម្បី ទទួលបន្ទុក នូវ ករណីយកិច្ច របស់ខ្លួន ជា ពលរដ្ឋៗ នៅក្នុងរបប លទ្ធិប្រជាធិបតេយ្យតំណាង វាមាន ការជ្រើសរើស អ្នកដឹកនាំ ដោយប្រជាពលរដ្ឋមានការចេះដឹង ដូច្នេះ ជា ជម្រើស ធ្វើសមោចនា (secréter) ចេញពី ប្រជាពលរដ្ឋ នូវ ពុធអ្នកដឹកនាំ សំរាប់ ដឹកនាំជាតិ មាន អាណត្តិ, ផ្ទុយទៅវិញ បើ ប្រជាពលរដ្ឋ គ្មាន ការចេះដឹង គឺ ច្បាស់ ជា មាន ទុរជន ឆ្លៀតយក ប្រព័ន្ធ ជ្រើសរើស នេះ ដើម្បី ដណ្ដើម អំណាច : ការជ្រើសរើស ដោយ សាកល ជា កម្លាំង នៃ ចំនួន, តែបើ ចំនួននោះ ជា ចំនួន ល្ងង់ខ្លៅ និង ខ្វាក់ប្រាជ្ញា គឺ នាំអោយ ដំណើរនៃប្រទេស ដើរ ឆ្ពោះទៅរក មហន្តរាយៗ ដូច្នេះ ការជឿ ទៅលើ វត្ថុ, គំនិត, អង្គការ, គណបក្សនយោបាយ, បុគ្គលណាមួយក្ដី វា ជា កម្លាំង ស្រូបចិត្ត អ្នកដទៃ អោយ ជឿលើខ្លួនៗ គុណភាព នៃ ការជឿ វា ស្ថិតនៅត្រង់ ថា អ្នកជឿ និង អ្នកអោយគេជឿ វា មាន ធាតុតែមួយ ហើយ មាន គោលដៅ តែមួយ, ជា ឧទាហរណ៍៖ ធាតុតែមួយ គឺ ប្រជាជាតិរួម, គោលដៅតែមួយ គឺ ប្រយោជន៍ជាតិៗ អ្នកអោយគេជឿ និង អ្នកជឿ ជា សរីរ: តែមួយ មាន ជីវិតតែមួយ គឺ ស្លាប់-រស់ ប្រកោះគ្នា តាមដង្ហើម នៃ ប្រជាជាតិ, ដូច្នេះ ការមាន សម្ពានទៅវិញទៅមក រវាង អ្នកទាំងពីរ គឺ ជា គុណភាព នៃ ដំណើរធម្មតា នៃ ប្រជាជាតិ មានសុខដុម ដែល តែងតែ ស្វែង រកជានិច្ច នូវ អ្វី ដែល ជា ដំណើរល្អ របស់ខ្លួន ដែលខ្លួនមានៗ ការ

ស្វែងរក នេះឯង គឺ ជា មគ្គនកម្ម (ការរើសសម្រាំង) យក គោលវិធីណា ដែល ល្អជាង គេ ក្នុងចំណោម គោលវិធី ល្អៗ ទាំងឡាយ ដែល ខ្លួនយល់ដឹង ដូចគ្នានឹង លទ្ធិប្រជាធិបតេយ្យ ពហុបក្ស មាន អ្នកបោះឆ្នោត ធ្វើការជ្រើសរើស គណបក្សនយោបាយ ណាមួយដែលខ្លួនទុកជា វរបក្ស សំរាប់ ដឹកនាំជាតិ មាន អាណត្តិៗ

**២. ការសង្ឃឹម ដល់ ជាតិ** : ដូចបានជំរាបខាងលើរួចហើយ ថា ការសង្ឃឹម ជា កម្លាំង ដែលមាននៅក្នុងបញ្ញា ដូច្នេះ កម្លាំងនេះ មិនមែនជាកម្លាំងអកម្ម គឺមានន័យថា មិនត្រឹមតែមាននៅក្នុងចិត្តនោះឡើយ គឺ ត្រូវតែ អនុវត្ត វា តាម បញ្ញា គឺមានន័យថា ជា កម្លាំង សកម្ម ដែល ធ្វើអោយ កម្លាំងនេះ ចេញពីចិត្ត ក្លាយ ជា កម្លាំងអំណាចបញ្ញា របស់ ប្រជាពលរដ្ឋ ដើម្បី ធ្វើ សមិទ្ធិកម្ម នូវ អ្វី ដែលខ្លួន ចង់បាន៖ អ្នកណា មានកម្លាំងចិត្ត ជា កម្លាំងអំណាចបញ្ញា សំរាប់ ស្វែងរកអ្វីមួយ ដែល ខ្លួនមានសង្ឃឹម តែង ទទួលបាន ដូចសេចក្តីប្រាថ្នាៗ អំណាចបញ្ញា តែងតែ រស់នៅក្បែរ ជានិច្ច នឹង ឆាពចាំបាច់ របស់ ប្រជាពលរដ្ឋ ព្រោះ ការខ្វះ របស់ចាំបាច់ ជាដំណើរ ឈានទៅរក ការចង់បាន, ដូច្នេះ ការសង្ឃឹម ឬ ការចង់បាន ជា កម្លាំងចិត្ត សកម្មពិត ដែលមិនអាចរលត់បាន នោះឡើយ ព្រោះអ្នកត្រូវការ របស់ចាំបាច់ តែងតែ មានសង្ឃឹម ហើយ ស្វែងរក ឬ អនុវត្ត ការចង់បាន នោះ ជា អនន្តរ និង អបរិយោសាន លុះបានសម្រេច ព្រោះ របស់ចាំបាច់ វា ជា រឿង ជីវិត ឬ រឿង ជាតិៗ

រួមសេចក្តីមក បើ មាន ការសង្ឃឹម តែ អង្គុយ ដេកចាំវា អោយកើតមកខ្លួនឯង ដូចខ្មែរ យើង នាំគ្នា រង់ចាំ ព្រះបាទធម្មិក ក្នុង ទុក្ខព្រួយខាងផ្លូវចិត្ត (tribulation) គឺច្បាស់ជា

ការរងចាំនោះ វា ជា ការសង្ឃឹម ក្នុងការរស់សង្ឃឹមតែប៉ុណ្ណោះៗ បើ មាន ការជឿ តែ ជឿទៅលើអ្វីមួយ ដែល មិនចេញមកពី អត្ត:បញ្ញា គឺ ជា ការជឿ គ្មានការពិចារណា ; ហេតុដូច្នេះ គឺ គ្មាន សេចក្តីស្នេហាឫាននោះទេ ព្រោះសេចក្តីស្នេហាជាតិ វា មានធាតុ ជាបញ្ញា, មិនមែន គ្រាន់តែ ដាំបង្កប់ ក្នុង ទឹកចិត្ត ; វា កើតមានឡើង ពី ការត្រិះរិះ ការ ពិចារណា ពិស្តារ មិនមែន ជា ឧបប្បាតិក (né de lui-même) ក្នុង ភាពចៃដន្យ សំរាប់ ល្បិតដោះខ្លួន ឬ ក្តុលគំនិត សម្របនឹង កាល:ទេស: អ្វីមួយ នោះឡើយៗ

យ៉ាងនេះ ការស្នេហាជាតិ, ការជឿលើជាតិ, ការសង្ឃឹមដល់ជាតិ វាជា សារព័នសណ្ឋិត ក្នុង ស្មារតី មាន បញ្ញាសត្តា របស់ ប្រជាពលរដ្ឋ ដែល ជា ប្រទព ថាមពល ជា ថេរ ចិរកាល រុញដំណើរ នៃ ប្រជាជាតិ អោយ ដើរ ទៅរក គោលដៅ នៃ ការរីកចំរើន ដែល ជា មនោមយិទ្ធ សន្និដ្ឋិក (pouvoir de la volonté visible) មាន សម្រេក និង ទំនាក់ចិត្ត នៃ មនុស្សជាតិៗ សារព័ន នេះឯង ជាសេចក្តីត្រូវការចាំបាច់ របស់ ប្រជាជាតិ និមួយៗ ដែលតម្រូវ អោយ ប្រជាពលរដ្ឋ មានចិត្តរំជួល ប្រកបដោយ សម្មានភាព នៃ ការស្នេហាជាតិ,ការជឿ និង ការសង្ឃឹម ជា បញ្ញា, ជា ការពិចារណា ដើម្បី ជា កម្លាំង ពនឹល សំរាប់ ធ្វើអភិវឌ្ឍន៏សង្គមជាតិ ដែលទុក មនុស្សលោក ជា ខ្លឹមសារ នៃ នរសង្គម ក្នុង បច្ចុប្បន្នសម័យ ក៏ដូចក្នុង អបរសម័យ លើ ក្រឡាប្រឹថពី នេះៗ នរសង្គមល្អ ជា ជម្រក ដ៏ប្រពៃ សំរាប់ មនុស្សលោក បីដូចប្រជាជាតិ ជា ផ្ទះសំបែង ដ៏សុខ សំរាប់ប្រជា ពលរដ្ឋ អម្បាលដូច មាតា ជា សេចក្តីស្នេហា សំរាប់កូនៗ ដូច្នេះ ការប្រៀបធៀប មាតា ទៅនឹងជាតិ គឺ ជា មនោសញ្ចេតនា នៃ សេចក្តីស្នេហា បរិសុទ្ធ និង ឧត្តមបំផុត របស់ ប្រជាពលរដ្ឋ ចំពោះ ជាតិ និង កូន ចំពោះ មាតាៗ៕